# ទស្សនៈព្រះពុទ្ធសាសនា

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

រៀបរៀងដោយ

សម្តេចព្រះមង្គលទេពាចារ្យ **អ៊ុំ ស៊ុម**

បោះពុម្ព

ចែកជាធម្មទានដោយលោក **ជា គាន**

ក្នុងឱកាសបុណ្យបញ្ចុះខណ្ឌសីមាវត្តព្រះពន្លៃ

២៥៧.
៩៣

ព.ស ២៥៤២ គ.ស ១៩៩៩

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។


សូមថ្លែងអំណរគុណដល់

**អង្គការរីហ្ស៊ូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។


Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.


A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.


www.budinst.gov.kh     www.elibraryofcambodia.org

២៥៧.៩៣

# ទស្សនៈព្រះពុទ្ធសាសនា

រៀបរៀងដោយ

សម្តេចព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម

បោះពុម្ព

ចែកជាធម្មទានដោយលោក ជា គាន

ក្នុងឱកាសបុណ្យបញ្ចុះខណ្ឌសីមាវត្តព្រះពន្លៃ

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
២៥៧៣/៩៩

ព.ស ២៥៤២ គ.ស ១៩៩៩



សម្តេចព្រះមង្គលទេពាចារ្យ

អ៊ុំ~ស៊ុំ

# នាមសប្បុរសជន

## មានសទ្ធាជ្រះថ្លាជួយចេញថ្លៃបោះពុម្ព

| | | |
|---|---|---|
| -លោក | ជា គាន | និង អ្នកស្រី ថាវន់ ចៅឡាច |
| -លោក | ជា សុខុម | និង អ្នកស្រី ឈុក ថាវី |
| -លោក | ញៀម ទាំឈី | និង អ្នកស្រី កៅ សាឡុន |
| -លោក | អ៊ុច សួរ | និង អ្នកស្រី គ្រី គន្ធា |
| -លោក | ឃិន ចំរើន | និង ប្អូន |
| -អ្នកស្រី | សូ បូរិន | និង មាតា |
| -អ្នកស្រី | ឈឹម សំពិសី | និង ស្វាមី |
| -លោក | ឃាស ឃួន | និង ភរិយា |
| -លោក | ឃាស សី | និង ភរិយា |
| -លោក | ពៅ ស្រ៊ុន | និង ភរិយា |

# អារម្ភកថា

សៀវភៅ "ទស្សនៈព្រះពុទ្ធសាសនា" នេះ គឺជាអត្ថបទធម៌មួយ ដែលសម្តេចព្រះមង្គលទេពាចារ្យ អ៊ុំ ស៊ុម បានស្រាវជ្រាវចងក្រង និងតម្រូវឱ្យខ្ញុំចាត់ចែងបោះពុម្ពចែកជាធម្មទាន ក្នុងឱកាសបុណ្យចំរើនព្រះជន្មរបស់ព្រះអង្គ ។

ខ្ញុំយល់ឃើញថា សៀវភៅទស្សនៈព្រះពុទ្ធសាសនានេះ ពិតមែនមានអត្ថបទខ្លី ប៉ុន្តែមានអត្ថន័យល្អជ្រាលជ្រៅ អាចឆ្លុះបំភ្លឺនូវខ្លឹមសារពិតនៃព្រះពុទ្ធសាសនា មានផលប្រយោជន៍ និង បានជាជំនួយស្មារតីយ៉ាងសំខាន់ដល់ការស្វែងយល់របស់ពុទ្ធបរិស័ទយើង ។

ក្នុងឱកាសបុណ្យបញ្ចុះខណ្ឌសីមាវត្ត ទ្រាំងពន្លៃ ឃុំអញ្ចើម ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដែលប្រព្រឹត្តទៅ នៅថ្ងៃ ២-៣-៤ និង ៥ រោច ខែចេត្រ ព.ស ២៥៤២ ត្រូវនឹងថ្ងៃទី ២-៣-៤ និងទី ៥ ខែមេសា ឆ្នាំ ១៩៩៩. ខ្ញុំមានសទ្ធាជ្រះថ្លា បានបោះពុម្ពអត្ថបទធម៌នេះជាថ្មី ដើម្បីចែកជូនជាធម្មទាន ឧទ្ទិសចំពោះព្រះពុទ្ធសាសនា និង សម្រាប់ជាគុណប្រយោជន៍ដល់ការស្រាវជ្រាវរបស់ពុទ្ធសាសនិកយើងតទៅអនាគត ។

ដោយសេចក្តីព្យាយាម ប្រកបដោយចិត្តជ្រះថ្លា ខ្ញុំសូមលើកយកកុសលនេះ ៖

-ជូនចំពោះ បុព្វការីទាំងឡាយ មានមាតាបិតា ជីដូនជីតា និង គ្រូឧបជ្ឈាយ៍ជាដើមរបស់ខ្ញុំ សូមវិញ្ញាណក្ខន្ធរបស់លោកទាំងនោះទទួលយកមនុញ្ញផលនេះ ហើយបានទៅសោយសុខក្នុងសុគតិភព ។

-សូមប្រគេន និងជូនកុសលនេះ ចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងពុទ្ធបរិស័ទទាំងអស់ សូមបានសម្រេចនូវពរទាំង ៥ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ ជានិច្ចនិរន្តរ៍ ។

សូមព្រះធម៌របស់ព្រះពុទ្ធបរមគ្រូ ជ្រួតជ្រាប និងស្ថិតនៅជាប់ជានិច្ច ក្នុងចិត្តគំនិតរបស់មនុស្សលោក ។

សូមព្រះរាជាណាចក្រកម្ពុជា សុខសន្តិភាព និងអភិវឌ្ឍន៍ ។

សូមព្រះពុទ្ធសាសនា រីកចំរើន និងស្ថិតនៅយូរអង្វែង

ថ្ងៃទី ២៧ ខែមីនា ព.ស ២៥៤២ / គ.ស ១៩៩៩

ខាំ គាន

# ប្រវត្តិសង្ខេប
## វត្តព្រះពន្លៃ

វត្តព្រះពន្លៃ មានទីតាំង ស្ថិតនៅភូមិពន្លៃ ឃុំអញ្ចើម ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ខាងត្បូងផ្លូវជាតិលេខ ៧ ចុះពីទីប្រជុំជនខ្ចារ ប្រមាណជាង ៥គ.ម ។

វត្តព្រះពន្លៃ ត្រូវបានកសាងឡើងតាំងពីក្នុងអំឡុងឆ្នាំ ១៩៣០ ដោយកំលាំងសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទចំណុះជើងវត្ត ដើម្បីទុកជាមរតកសាសនា ដ៏មានតំលៃ ភ្ជាប់ទៅនឹងព្រលឹងជាតិនៃបុព្វបុរសយើង ក្រោមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ និង ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការបំពេញបុណ្យកុសលផ្សេងៗ តាមប្រពៃណីព្រះពុទ្ធសាសនា ។

ដើមឡើយ. វត្តព្រះពន្លៃ មានការរីកចំរើនយ៉ាងខ្លាំង ដោយមានព្រះវិហារ កុដិ សាលា ទីសេនាសនៈផ្សេងៗ ដ៏សមរម្យ គួរជាទីតង់ស្នាក់អាស្រ័យនៅសិក្សារៀនសូត្ររបស់ភិក្ខុសាមណេរ ដែលនិមន្តមកអំពីទិសទាំងបួន និង ជាទីអារាមគួរជាទីរីករាយជ្រះថ្លារបស់ឧបាសក ឧបាសិកា ទាយក ទាយិកា និងពុទ្ធបរិស័ទជិតឆ្ងាយ ក្នុងការបំពេញកុសលកម្មផ្សេងៗ តាមជំនឿសាសនា ។

ជាអកុសល ក្នុងអំឡុង ៣ឆ្នាំ ៨ខែ ២០ថ្ងៃ. ក្រោមរបបប្រល័យពូជសាសន៍ ប៉ុល ពត. វត្តព្រះពន្លៃ ក៏ដូចជាវត្តនានា នៅក្នុងទូទាំងប្រទេស ត្រូវទទួលគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ដោយត្រូវពួកឥតសាសនា បំផ្លិចបំផ្លាញស្ទើរគ្មានសល់ ។ កុដិ សាលា ព្រះវិហារ ព្រះពុទ្ធបដិមា គម្ពីរ ដីកា ក្បួនច្បាប់ពុទ្ធសាសនាផ្សេងៗ ត្រូវបំផ្លិចបំផ្លាញ និងកំទេចចោលយ៉ាងព្រៃផ្សៃបំផុត ។

ប៉ុន្តែ ជាភ័ព្វសំណាង និងជាបុណ្យកុសលដ៏ថ្លៃថ្លា. ថ្ងៃ ២ធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ត្រូវបានបង្កើតឡើង ក្រោមការដឹកនាំរបស់ សម្តេច ហេង សំរិន. សម្តេច ជា ស៊ីម សម្តេច ហ៊ុន សែន និងបាន ធ្វើការអំពាវនាវកំលាំងមហាសាមគ្គីប្រជាជាតិទាំងមូល វាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ឱ្យរលំរលាយទាំងស្រុង នាថ្ងៃ ៧ មករា ១៩៧៩ ។

ក្រោយថ្ងៃជ័យជំនះ ៧ មករា អ្វីៗ ទាំងអស់ត្រូវបានរស់រានមានជីវិតឡើងវិញ ។ ព្រះពុទ្ធសាសនា ដែលជាជំនឿភ្ជាប់ទៅនឹងជីវភាពរស់នៅដ៏យូរលង់របស់ប្រជាពលរដ្ឋខ្មែរ ក៏ត្រូវបានរៀបចំឱ្យមានឡើងវិញ បើកទូលាយប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទគោរពបូជា តាមជំនឿ និងប្រពៃណី ។

រីឯ វត្តព្រះពន្លៃ នេះ ក៏ត្រូវបានអាចារ្យ គណៈកម្មការ និងពុទ្ធបរិស័ទចំណុះជើងវត្ត រៀបចំឡើងវិញ និងបាននិមន្តព្រះសង្ឃមកគង់នៅធ្វើបុណ្យកុសលរៀងរហូតមក ។

ក្នុងជំហានចាប់ផ្តើមដំបូង. អាចារ្យ គណៈកម្មការ និងពុទ្ធបរិស័ទចំណុះជើងវត្ត បានត្រឹមតែកសាងសាឡាមដ៏តូចមួយជាបណ្តោះអាសន្ន សម្រាប់សង្ឃធ្វើសង្ឃកម្មផ្សេងៗ និងកសាងកុដិមួយ សម្រាប់ព្រះសង្ឃគង់ស្នាក់នៅបណ្តោះ ។

លុះក្រោយមក. ក្នុងឆ្នាំ ១៩៩២ ព្រះសង្ឃ អាចារ្យ គណៈកម្មការ និងពុទ្ធបរិស័ទចំណុះជើងវត្ត ក៏បានចាប់ផ្តើមកសាងឡើងវិញនូវព្រះវិហារ ដែលជាឧបោសថាគារ ជាគោលចារិកនៃវត្តនេះ នៅលើខឿនចាស់ និង បានរួចរាល់ហើយស្រេចជាស្ថាពរនៅឆ្នាំ ១៩៩៨ ព្រមទាំងបានប្រារព្ធពិធីបុណ្យបញ្ចុះខណ្ឌសីមា នៅថ្ងៃ ២-៣-៤ និង ៥ រោច ខែចេត្រ ព.ស ២៥៤២ ត្រូវនឹងថ្ងៃទី ២-៣-៤ និង៥ ខែមេសា ឆ្នាំ ១៩៩៩ ដើម្បីបើកឱ្យប្រើប្រាស់តាមពុទ្ធានុញ្ញាត និងពុទ្ធប្បញ្ញត្តិ ។

មូលដ្ឋានសម្ភារៈ និងផលិកា បំរើការកសាងព្រះវិហារនេះ បានមកពីការជួយឧបត្ថម្ភដ៏ថ្លៃថ្លារបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងលោកជំទាវ. ឯកឧត្តម គន់ គីម និងលោកជំទាវ. ឯកឧត្តម អ៊ឹុច សាមី និងលោកជំទាវ. ព្រមទាំងកំលាំងសទ្ធាជ្រះថ្លាដ៏ជ្រាលជ្រៅរបស់ពុទ្ធបរិស័ទចំណុះជើងវត្តព្រះពន្លៃទាំងមូល និងពុទ្ធបរិស័ទនៅរាជធានីភ្នំពេញ និងខេត្តផ្សេងៗទៀតដែលបានចូលចាប់កុសលតាមកំលាំងសទ្ធារៀងៗខ្លួន ។

ព្រះសង្ឃ អាចារ្យ គណៈកម្មការ និងពុទ្ធបរិស័ទចំណុះជើងវត្តព្រះពន្លៃទាំងមូល សូមសំដែងនូវមនោសញ្ចេតនារីករាយជាអនេកប្បការ ចំពោះសម្តេច ហ៊ុន សែន និងលោកជំទាវ. ឯកឧត្តម គន់ គីម និងលោកជំទាវ. ឯកឧត្តម អ៊ឹុច សាមី និងលោកជំទាវ ព្រមទាំងសប្បុរសជនទាំងអស់ ដែលបានជួយកសាងព្រះវិហារវត្តព្រះពន្លៃនេះឱ្យសម្រេចជាស្ថាពរ ប្រកបដោយសោភណភាពគួររីករាយនិងគួរជាទីជ្រះថ្លា ឆ្លើយតបយ៉ាងសក្តិសមទៅ និង សំណូមពរចាំបាច់របស់ប្រជាពលរដ្ឋជាពុទ្ធបរិស័ទយើង ។

សូមលើកយកកុសលទាំងនេះ ប្រគេនព្រះសង្ឃគ្រប់អង្គ ជូនសម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងពុទ្ធបរិស័ទទាំងអស់ សូមបានប្រកបដោយពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈជានិច្ចនិរន្តរ៍ ។

វត្តព្រះពន្លៃ, ថ្ងៃទី ២៧ ខែមីនា ព.ស ២៥៤២ / គ.ស ១៩៩៩

អ្នករៀបរៀង

ខៀ គាន

# ទស្សនៈព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាជាសាសនាមួយ សម្បូរពាក្យប្រៀនប្រដៅដែលប្រកបដោយខ្លឹមសារ មានសារប្រយោជន៍ មានតម្លៃខ្ពង់ខ្ពស់ច្រើនណាស់។ មានពាក្យប្រៀនប្រដៅខ្លះ ត្រូវគ្នានឹងពាក្យប្រៀនប្រដៅរបស់អ្នកប្រាជ្ញទាំងឡាយអំពីបុរាណដែលមនុស្សលោកគេបានចេះចាំរៀងៗមក តាំងអំពីមុនពុទ្ធកាលក៏មាន ។ មានពាក្យប្រៀនប្រដៅខ្លះខ្ពង់ខ្ពស់បំផុត ហួសពីគំនិតរបស់មនុស្សបុថុជ្ជនទាំងអស់ដែលក្រៅអំពីព្រះសម្ពុទ្ធចេញ ឥតមានអ្នកណាមួយមានគំនិតគិតឃើញ មានសមត្ថភាព យល់យល់ចាក់ធ្លុះដឹងច្បាស់នូវអាថ៌កំបាំងដ៏ជ្រាលជ្រៅបានឡើយ ។

ព្រះពុទ្ធសាសនា មានកំណើតនៅមជ្ឈិមប្រទេស ។ មុនដែលព្រះពុទ្ធសាសនាមិនទាន់កើតឡើង មនុស្សទូទៅនៅអាស្រ័យក្នុងប្រទេសនោះបាននាំគ្នាប្រព្រឹត្តប្រតិបត្តិតាមលទ្ធិសាសនាព្រាហ្មណ៍ខ្លះ តាមសាសនាដទៃទៀតខ្លះ ដែលជាផ្លូវប្រតិបត្តិតឹងពេកក៏មាន ធូរពេកក៏មាន ដូចជាប្រព្រឹត្តអត់អាហារធ្វើអោយលំបាកវេទនារាងកាយខ្លួនឯងឥតអំពើ ដេកលើបន្លា ចុះត្រាំទឹកដើម្បីលាងជម្រះបាប អាំងភ្លើងនៅវេលាថ្ងៃក្នុងគិម្ហរដូវជាដើម ។

នោះបីប្រព្រឹត្តបែបនេះ ដែលគ្មានបានផល គ្មានឃើញកើតប្រយោជន៍សូម្បីបន្តិចបន្តួចក៏ដោយ ក៏ឥតមានជនណាម្នាក់រលឹក មានគំនិតគិតឃើញ ហើយនាំគ្នាវៀរលាស់ខ្លួនងាកទៅប្រតិបត្តិតាមបែបថ្មីទៀតសោះឡើយ ។

លុះមកដល់សម័យដែលព្រះសម្ពុទ្ធបានត្រាស់ដឹងឡើង ទ្រង់បានសំដែងធម៌ជាលើកដំបូងប្រោសភិក្ខុចំនួន ៥រូប ហៅថាធម្មចក្កប្បវត្តនសូត្រ ដើម្បីកែប្រែវិធីប្រតិបត្តិដ៏សៅហ្មងគ្រោតគ្រាតទាំងនោះចោលចេញ ហើយអោយកែប្រែចិត្តគំនិតគិតខុសទាំងនោះ អោយប្រព្រឹត្តតាមគន្លងធម៌ ដែលព្រះអង្គយល់ជ្រាបច្បាស់ថា មានប្រយោជន៍ទៅវិញ ។

ធម៌ទេសនាជាបឋមនោះ ទ្រង់ត្រាស់សំដែងថា ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា ម្នាលភិក្ខុទាំងឡាយ ធម៌ជាផ្លូវប្រតិបត្តិអមខាងដ៏លាមកអាក្រក់ទាំងឡាយពីរប្រការនេះ បព្វជិតមិនគួរសេពគប់ គឺមិនគួរប្រព្រឹត្តធ្វើឡើយ :

១- អត្តកិលមថានុយោគ : ការប្រព្រឹត្តធ្វើខ្លួនអោយលំបាក ។ ធម៌នេះ គឺជាឈ្មោះនៃទ្រឹស្តីទាំងមូលរបស់សាសនាព្រាហ្មណ៍ បានជាព្រះសម្ពុទ្ធត្រាស់ដូច្នេះ ពីព្រោះសាសនាព្រាហ្មណ៍គេបានប្រព្រឹត្តធម៌ពីរយ៉ាងគឺ :

ក- តបះ គឺជាកិច្ចការ ឬជាវិន័យ ដែលពួកអ្នកកាន់សាសនា

ព្រាហ្មណ៍ត្រូវតែធ្វើអោយដូចជាពួកអចេលក៏ មិនស្លៀកពាក់ខោអាវ អាំងភ្លើង ឈរហាលថ្ងៃ ចុះត្រាំទឹក ប្រព្រឹត្តអត់អាហារ ។ ដូច្នេះជាពិធីដើម្បីហាត់ពត់ចិត្តរបស់គេអោយអស់កិលេស ។ ព្រះសម្មទ្ធទ្រង់រិះគន់ថាធម៌នេះជាធម៌ថោកទាបលាមក ដែលមនុស្សទូទៅមិនគួរនឹងយកខ្លួនទៅលាយឡំទេ ។ នៅក្នុងលទ្ធិសាសនាព្រាហ្មណ៍ ក្នុងសម័យព្រាហ្មណ៍ គេមានធម៌ជាពិធីទូន្មានខាងផ្លូវកាយ ។

១- យោគៈ ពួកអ្នកកាន់សាសនាព្រាហ្មណ៍ ដោយយល់ឃើញថា តបវិធី ជាវិធីគ្រាន់តែទូន្មានផ្លូវកាយ មិនមានប្រសិទ្ធិភាពដល់ទៅផ្លូវចិត្តផងទេ គេក៏នាំគ្នាធ្វើពិធីមួយទៀតដែលហៅថា យោគៈ សំរាប់អប់រំផ្លូវចិត្ត ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ការអប់រំផ្លូវចិត្តនេះ នៅតែមិនអាចធ្វើចិត្តអោយជ្រះស្រឡះរកមោក្ស ឬនិព្វាននេះបានឡើយ ។

២- កាមសុខល្លិកានុយោគៈ នេះជាទ្រឹស្តីរបស់ពួកសាសនាព្រាហ្មណ៍ដែរ គ្រាន់តែជួយនឹងទស្សនៈខាងដើម ។ ទស្សនៈនេះនាំអោយយល់នូវគោលគំនិត និង បុព្វហេតុដែលនាំអោយគេបានទទួលនូវសុភមង្គលមានជាអាទិ៍ថា បុព្វហេតុនៃសុភមង្គល ស្ថិតនៅលើបុគ្គលម្នាក់ ។ ដែលចេះលៃលកយ៉ាងណាអោយសម្បូរដោយគ្រឿងកាម គ្រឿងសប្បាយ ដូចជាស៊ីផឹកឆ្ងាញ់ពិសារ ស្លៀកពាក់ហ៊ឺហា ទីលំនៅឧត្តុង្គឧត្តមប្រសើរឡើង ។ ការស៊ីឆ្ងាញ់ ការដេកស្រួល ការប្រើប្រាស់នូវវត្ថុល្អ នឹងនាំអោយគេបាន

សុខចំរើនគ្រប់វិស័យ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់រិះគន់នូវគោលនៃលទ្ធិនេះថា ជាគំនិតថោកទាប អពមង្គល ឈមមុខឆ្ពោះទៅរកសេចក្តីវិនាសទាំងអស់។

ដោយគោលគំនិតពីរខាងលើ ជាគោលគំនិតជ្រុលបំផុត និង ស្តាំបំផុត ទើបព្រះពុទ្ធជាម្ចាស់ទ្រង់បានប្រកាន់យកផ្លូវកណ្តាលវិញ សំរាប់ធ្វើជាមធ្យោបាយដឹកនាំមនុស្សអោយប្រព្រឹត្តទៅបានដោយស្រួល ។ ករណីទាំងពីរខាងលើនេះ បើប្រៀបធៀបទៅនឹងជីវភាពរបស់ព្រះអង្គកាលពីខាងដើមក៏មានការស្របគ្នាដែរ :

- ខណៈទីមួយ គឺព្រះអង្គទ្រង់គង់នៅក្នុងរាជសម្បត្តិដែលជារយៈពេលសប្បាយកាមគុណ ។

- ខណៈទីពីរ គឺរយៈពេលដែលព្រះអង្គចេញសាងផ្នួស ធ្វើទុក្ករកិរិយាយ៉ាងតឹងរ៉ឹងពេក ។

រយៈពេលទាំងពីរនេះ លុះព្រះអង្គបានត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គទ្រង់រិះគន់ថា ជាអំពើថោកទាប មិនមែនជាផ្លូវប្រតិបត្តិ មិនមានប្រយោជន៍សំរាប់អ្នកប្រតិបត្តិទេ ព្រះអង្គក៏ជ្រើសរើសយកផ្លូវប្រតិបត្តិកណ្តាលវិញ ។

ឯផ្លូវកណ្តាលនោះមាន ៨ យ៉ាង ៖

១. *សម្មាទិដ្ឋិ* ការយល់ឃើញត្រូវ ១

២. *សម្មាសង្កប្បៈ* សេចក្តីត្រិះរិះត្រូវ ១

៣- សម្មាវាចា     សម្ដីត្រូវ ១

៤- សម្មាកម្មន្តៈ     ការងារត្រូវ ១

៥- សម្មាអាជីវោ     ការចិញ្ចឹមជីវិតត្រូវ ១

៦- សម្មាវាយាមៈ     ព្យាយាមត្រូវ ១

៧- សម្មាសតិ     សេចក្ដីរលឹកត្រូវ ១

៨- សម្មាសមាធិ     ការតម្កល់ចិត្តអោយនឹងត្រូវ ១ ។

ផ្លូវកណ្ដាលនេះហៅថា អដ្ឋង្គិកមគ្គ ជាផ្លូវប្រសើរខ្ពង់ខ្ពស់ស្អាតត្រង់ដែលព្រះអរហន្តទាំងឡាយមានព្រះសម្ពុទ្ធជាដើម ព្រះអង្គបានដើរប្រកបដោយសុខស្រួល ហើយចង្អុលបង្ហាញប្រាប់ដល់ពុទ្ធបរិស័ទទាំងឡាយថា នែអ្នកទាំងឡាយ ចូរដើរទៅតាមផ្លូវនេះចុះ ។

នៅមានធម៌ដែលជាពុទ្ធសាសនាម៉ាងទៀត ដែលហៅថា សច្ចៈ ជាធម៌ប្រកាសនូវពាក្យពិត ពាក្យមែន ។

បញ្ហាសច្ចៈនេះ បានចោទឡើងនៅក្នុងសង្គមមនុស្សគ្រប់មជ្ឈដ្ឋាន បាននាំអោយអ្នកប្រាជ្ញទាំងឡាយក្នុងលោកចោទ និង ដោះស្រាយទៅវិញទៅមកមិនឈប់ឈរ ដើម្បីស្វះស្វែងរកសច្ចៈនេះ ។ យើងអាចចោទសួរថា សច្ចៈជាអ្វី ? អ្នកណាបង្កើតពាក្យសច្ចៈ ? សច្ចៈនេះមាននៅក្នុងលោកនេះ ឬក្នុងលោកខាងមុខ ? ស្ថិតនៅក្នុងសង្គមមនុស្ស ឬនៅលើបុគ្គលម្នាក់ៗ ? ឬក៏ស្ថិតនៅក្នុងវត្ថុធម្មជាតិគ្រប់បែបយ៉ាង ? ដរាបណា

មានបញ្ហានេះចោទឡើងនោះ យើងត្រូវតែខំប្រឹងប្រើមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីវែកញែកឆ្ពុះមើលសច្ចៈនេះអោយឃើញច្បាស់ ។ មជ្ឈដ្ឋានសាសនា " ពួកពាហិរសាសនា " គេបានអះអាងថា សច្ចៈ ស្ថិតនៅលើព្រះអាទិទេព ។ អាទិទេព គឺជាតួព្រះបរិបុណ្ណសច្ចៈ គេខំប្រឹងប្រតិបត្តិគ្រប់បែបយ៉ាង គឺដើម្បីមើលអោយឃើញព្រះអាទិទេពនេះឯង ។ ដរាបណាគេមើលឃើញព្រះអាទិទេព គេក៏បានទទួលនូវសច្ចៈដែរ គឺបានសុខសំរេចដល់មោក្ខៈ ។ មជ្ឈដ្ឋានអ្នកទស្សនវិទូភាគខ្លះ ដែលមិនទាក់ទងទៅនឹងសាសនា បានខំពន្យល់ថា សច្ចៈ ស្ថិតនៅក្នុងសង្គមមនុស្សនេះឯង ។ ដរាបណា គេខំរចនាសង្គមមនុស្សឱ្យបានស្អាតបរិសុទ្ធ ប្រាសចាកអំពើអយុត្តិធម៌ សម្របសម្រួលនូវជីវភាពរបស់មនុស្សឱ្យបានស្រួល ដរាបនោះឯង សច្ចៈនឹងកើតឡើងភ្លាម ។ មូលដ្ឋាននៃសច្ចៈ ក្នុងសង្គមមនុស្សនេះពោល គឺ ចរិយា សីលធម៌ នេះឯង ។ ទស្សនវិទូប្រភេទនេះ សង្កត់ខ្លាំងទៅលើសង្គមមនុស្ស ជីវភាពមនុស្សធម្មតា ដោយគេខំពន្យល់តែអំពីវិបត្តិគ្រប់បែបយ៉ាងដែលប៉ះពាល់សង្គមមនុស្ស បើគេដកចេញនូវអ្វីដែលជាវិបត្តិនេះហើយ ពេលនោះគេនឹងរកឃើញនូវអ្វីដែលជាសុខ ។

មជ្ឈដ្ឋានអ្នកវិទ្យាសាស្ត្រ ដើម្បីទាញយកសច្ចៈបានគេត្រូវធ្វើការពិសោធន៍ ។ ក្រោយពីការពិសោធន៍ គេបានលទ្ធផលយ៉ាងណា លទ្ធផលនោះឯងជាសច្ចៈ។ ពួកអ្នកវិទ្យាសាស្ត្រសម្ភារៈនិយម គេអោយតម្លៃជាចំខាត

ទៅលើការពិសោធន៍ជាក់ស្តែង។ ដរាបណា គេធ្វើការពិសោធន៍ទៅអោយផលមិនទៀងទាត់ ម្តងយ៉ាងនេះ ម្តងយ៉ាងនោះ គេមិនទទួលថា សច្ចៈឡើយ ។ នឹងទទួលជាសច្ចៈបាន លុះត្រាតែមានសភាពពិតដូចជា ២ × ២ ＝ ៤ ។

ចំណែកសច្ចៈនៅក្នុងព្រះពុទ្ធសាសនា ដែលហៅថា សច្ចៈធម៌ដែរព្រះពុទ្ធបរមគ្រូនៃយើងបានស្រាវជ្រាវរាវរកអស់រយៈ ៦ ឆ្នាំទើបឃើញនោះមាន ៤ ប្រការ គឺ ៖

***ទុក្ខសច្ចៈ*** ទុកជារបស់ពិត ពីព្រោះចេះតែតាមបៀតបៀន

***សមុទយសច្ចៈ*** គឺ តណ្ហា នាំអោយកើតទុក្ខ ជាសេចក្តីពិតពីព្រោះចេះតែនាំអោយស្ងួនស្ងោរ អន្ទះសារ ។

***និរោធសច្ចៈ*** ព្រះនិព្វានជាកន្លែងរំលត់ទុក្ខ ជាសេចក្តីពិតពីព្រោះវាអស់ពូជបន្ត ។

***មគ្គសច្ចៈ*** ផ្លូវនាំទៅកាន់ទីរំលត់ទុក្ខ ជាសេចក្តីពិត ពីព្រោះផ្លូវនោះត្រង់ ហើយស្អាតពិសេស ។

សច្ចៈធម៌ ទាំងបួនប្រការនេះ ជាធម៌មានអាថ៌ជ្រាលជ្រៅកំបាំងនឹងគំនិតប្រាជ្ញារបស់មនុស្សបុថុជ្ជនធម្មតាទាំងអស់ ។ ពេលដែលមិនទាន់មានព្រះពុទ្ធសាសនា ឥតមានអ្នកណាមួយស្រាវជ្រាវរាវរកឃើញសច្ចធម៌នេះ

ឡើយ ។ លុះដល់ព្រះសម្ពុទ្ធបានត្រាស់ដឹងឡើងក្នុងលោក ទើបទ្រង់សំដែងសច្ចធម៌នេះអោយមនុស្សទាំងអស់បានស្គាល់ច្បាស់លាស់ប្រាដកក្នុងខ្លួន ។

សច្ចធម៌ទាំង ៤ ប្រការនេះហើយ ដែលអ្នកមានប្រាជ្ញាទាំងឡាយ បានឮបានស្គាល់ហើយគិតពិនិត្យតាមផ្លូវធម៌នេះទៅ ក៏យល់ដោយប្រត្យក្ស ថាជាធម៌ពិតមែន ។

នៅមានទស្សនៈពុទ្ធសាសនាម៉្យាងទៀត ដែលសំរាប់អប់រំមនុស្សអោយចេះគិតគូរពិចារណាដល់រូបរាងកាយអោយឃើញថា មិនទៀង ជាទុក្ខ និងមិនមែនជារបស់ខ្លួន ដែលមានឈ្មោះថា ព្រះត្រៃលក្ខណ៍ ដើម្បីកុំអោយមានសេចក្តីស្រឡាញ់ក្នុងរូបរាងកាយខ្លាំងពេក ។

ម៉្យាងទៀត ព្រះពុទ្ធសាសនាប្រៀនប្រដៅមនុស្សអោយឃើញប្រយោជន៍ អោយបានសេចក្តីសុខ ពុំមែនតែក្នុងអនាគតខាងមុខដែលយើងមើលមិនឃើញប៉ុណ្ណោះទេ គឺក្នុងបច្ចុប្បន្នធ្វើរិតតែជាក់ច្បាស់លាស់ ដូចជាទ្រង់ប្រដៅមនុស្សមិនអោយប្រព្រឹត្តនូវអបាយមុខ ៦ យ៉ាង គឺៈ មិនអោយផឹកសុរា ១, មិនអោយដើរលេងតាមច្រកល្ហកនៅវេលាយប់ ១, មិនអោយដើរលេងល្បែងមហោស្រពឥតប្រយោជន៍ ១, មិនអោយលេងល្បែងភ្នាល់មានបៀរចៅជាដើម ១, មិនអោយសេពគប់មនុស្សខូចយកធ្វើជាមិត្តភក្តិ ១, មិនអោយខ្ជិលធ្វើការងារបង្កបង្កើនផល ១, ។

ប៉ុណ្ណេះជាដើម សុទ្ធតែនាំមនុស្សអ្នកប្រព្រឹត្តតាម អោយបានប្រយោជន៍ដ៏ខ្ពង់ខ្ពស់និងសេចក្ដីសុខគួរជាទីប្រាថ្នានៅក្នុងបច្ចុប្បន្ននេះឯង ។

ជាពិសេសទៅទៀតនៅពេលដែលទ្រង់រៀបនឹងបរិនិព្វាន ព្រះអង្គបានត្រាស់ផ្ដាំចំពោះពុទ្ធបរិស័ទទាំង ៤ ថា :

" សង្ខារធម៌ទាំងឡាយដែលកើតឡើងហើយ តែងតែវិនាសទៅវិញជាធម្មតា អ្នកទាំងឡាយចូរបំពេញនូវភារកិច្ចរៀងៗខ្លួន អោយសំរេចជាស្ថាពរឆាប់ ដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ចុះ " ។

បច្ឆិមពុទ្ធវចនៈនេះ ជាទស្សនៈពុទ្ធសាសនាម្យ៉ាង ដែលមានប្រយោជន៍ ប្រកបដោយខ្លឹមសារជាទីបំផុត ។ ព្រះពុទ្ធដីកានេះ ព្រះអង្គចង់បញ្ជាក់ថា យើងដែលមានជាតិជាមនុស្ស មិនត្រូវដេកស្ងៀម ឈរអោបដៃមើល ដកដង្ហើមចោលទទេ គ្មានស្មារតីប្រុងប្រយ័ត្នទេ គឺត្រូវក្រោកឡើងខំប្រឹងប្រកបការងារផ្សេងៗ ដើម្បីជាប្រយោជន៍សំរាប់ខ្លួនរៀងៗខ្លួនកុំបង្អែបង្អង់ឡើយ ។

ការងារទាំងនេះ បើជនណាបានធ្វើ បានជួយឧបត្ថម្ភគ្នាទៅវិញទៅមក តាមកំលាំង និងសមត្ថភាពរបស់ខ្លួននោះ បើទុកជាស្លាប់ទៅគ្រាន់តែអស់ខ្យល់ដកដង្ហើមចេញចូលប៉ុណ្ណោះ ក៏ប៉ុន្តែទុកដូចជាមានជីវិតរស់នៅដែរ ពីព្រោះ **អប្បមាទោ អមតំ បទំ** ការមិនប្រមាទ គឺមានស្មារតីប្រុងប្រយ័ត្នជានិច្ច ជាមូលដ្ឋាននៃការមិនស្លាប់ អ្នកណាមានស្មារតីប្រុង

ប្រយ័ត្នជានិច្ច អ្នកនោះឈ្មោះថាមិនចេះស្លាប់ ។ បើទុកជាស្លាប់ហើយ ក៏ដូចជាមានជីវិតរស់នៅដែរ ។

ចំណែកអ្នកដែលគ្មានស្មារតីប្រុងប្រយ័ត្ន បើទុកជារស់នៅ ក៏ដូចជាស្លាប់ទៅហើយ ពីព្រោះសេចក្តីប្រមាទ គឺការមិនប្រុងប្រយ័ត្នស្មារតីជាមូលដ្ឋាននៃសេចក្តីស្លាប់ ។ **អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំ វ រក្ខតិ** អ្នកប្រាជ្ញតែងរក្សាទុកនូវការប្រុងប្រយ័ត្ន ដូចជាគេរក្សាទុកនូវទ្រព្យដ៏ប្រសើរ ។

ដោយសម្តេចព្រះមង្គលទេពាចារ្យ អ៊ុំ ស៊ុម សង្ឃត្ថេរា
ចៅអធិការវត្តមហាមន្ត្រី រាជធានីភ្នំពេញ
ថ្ងៃ ព្រហស្បតិ៍ ៤ កើត ខែកត្តិក ឆ្នាំ ជូត អដ្ឋស័ក
គឺ ថ្ងៃទី ១៤ វិច្ឆិកា ២៥៤០ / ១៩៩៦